ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សអ
MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ១៤ សកបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០២

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់ដែលមានចែងនៅក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារបានជ្រាបថា ដើម្បីអនុវត្តមាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា២៥ មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៣០ និងមាត្រា៣១ នៃច្បាប់ស្តីពីការងារអោយបានត្រឹមត្រូវ និងទទួលលទ្ធផលល្អ ក្រសួងសូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ខាងលើអនុវត្តដូចតទៅៈ-

១-ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចពោលខាងលើដែលមានប្រើកម្មករនិយោជិតយ៉ាងតិច ប្រាំបីនាក់ ឡើងទៅត្រូវតែរៀបចំអោយមានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសមួយជាដរាប ។

២-បទបញ្ជាផ្ទៃក្នុងត្រូវអនុវត្តបទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីការងារ តាមប្រភេទសហគ្រាស គ្រឹះស្ថាន អនុសញ្ញារួមនៃការងារ និងវិធានទូទៅនៃការងារដែលស្តីពីផ្នែកសកម្មភាពនៃសហគ្រាស គ្រឹះស្ថានជាអាទិ៍គឺ បទប្បញ្ញត្តិទាក់ទងនឹងលក្ខខណ្ឌទទួលធ្វើការ ការគិត និងការបើកប្រាក់ឈ្នួល កំរៃបន្ទាប់បន្សំទាក់ទងនឹងតាវ៉កាលិកធម្មជាតិ ពេលម៉ោងធ្វើការ ពេលសំរាក និងការឈប់សំរាក ការអោយដំណឹងមុន បទបញ្ជា និងវិធានខាងអនាម័យ និងសន្តិសុខកម្មករនិយោជិត កាតព្វកិច្ចកម្មករនិយោជិត និងទណ្ឌកម្មដែលនឹងអាចគំរូវលើកម្មករនិយោជិត ដូចមានគំរូជាឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងនេះ ។

Labour Dispute Resolution Project
RECEIVED
No. 055
Date 26-08-02

៧-សេចក្តីជូនដំណឹងរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ១២ សកអ. ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ និងលេខ ០៩ សកអ. ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាសង្ឃឹមថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ អោយបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពខ្ពស់ជាពុំខាន។៚

រដ្ឋមន្ត្រី

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធ

នៃសេចក្ដីជូនដំណឹងលេខ....១៤......សកបយ.

ចុះថ្ងៃទី...១៦...ខែ.សីហា....ឆ្នាំ២០០២

(គំរូនៃបទបញ្ជាផ្ទៃក្នុង)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## បទបញ្ជាផ្ទៃក្នុង

របស់សហគ្រាស.............................................................................

### I. បទបញ្ញត្តិស្ដីពីវិន័យការងារ

ប្រការ១ :
- លក្ខខណ្ឌទទួលយកនិយោជិត កម្មករអោយធ្វើការ
- បែបបទផ្សេងៗដែលនិយោជិត កម្មករត្រូវបំពេញមុនចូលបំរើការងារ
- អាសយដ្ឋានរបស់និយោជិត កម្មករ ស្ថានភាពគ្រួសារ ការផ្លាស់ប្ដូរផ្សេងៗនៅពេលក្រោយមកទៀត
- ការហ្វឹកហ្វឺនកូនជាង
- ការសាកល្បងការងារ ។

ប្រការ២ :
- បែបបទនៃការអនុវត្តន៍ការងារក្នុងសហគ្រាស គ្រឹះស្ថាន
- របៀបរបប និងសណ្ដាប់ធ្នាប់ល្អនៅក្នុងសហគ្រាស គ្រឹះស្ថាន ។

ប្រការ៣ :
- ការពិនិត្យកាយសម្បទានៅគ្រាដំបូង
- ការពិនិត្យសុខភាពជាកាលិក ។

ប្រការ៤ :
- ពេលម៉ោងធ្វើការ គិតទាំងការធ្វើការនៅពេលយប់ និងការប្ដូរវេនធ្វើការ
- ការឈប់សំរាកប្រចាំសប្ដាហ៍
- ការឈប់សំរាកប្រចាំឆ្នាំ ឈប់សំរាកពេលបុណ្យ ឈប់សំរាកពិសេស
- ការសំរាកសំរាលកូនរបស់និយោជិត កម្មករជាស្ត្រី